**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១៣៧៩ កសក　　　　　　　　　　　　　　　　　　　　　　　　រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៥

**សូមគោរពជូន**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

**-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃព្រឹទ្ធសភា**

**-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃរដ្ឋសភា**

**-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**-ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា**

**-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**

**-ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់**

**កម្មវត្ថុ ÷** របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥** និងទិសដៅអនុវត្តបន្ត ។

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមផ្ញើជូនឯកឧត្តម នូវរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**ចម្លងជូន**

-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង

-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា　ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia　Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងខែកុម្ភៈ ឆ្នាំ២០១៥នេះ ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងបានបញ្ចប់ចំនួន១១ខេត្តហើយ ប្រជាកសិករបាននឹងកំពុងដំណើរការច្រូតកាត់ជាបណ្តើរៗ។ ជាមួយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តជំរុញការណែនាំដល់ប្រជាកសិករឲ្យខិតខំបង្កើនការថែទាំដំណាំស្រូវប្រាំង ក៏ដូចជាដំណាំផ្សេងៗទៀត ធ្វើកសិកម្មចម្រុះនៅតាមតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់និងការរៀបចំទុកដាក់ក្រោយពេលប្រមូលផលឲ្យបានសមស្របតាមបច្ចេកទេស។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចាត់ក្រុមការងារចុះណែនាំ ជំរុញអង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ឲ្យចុះដល់មូលដ្ឋានជាប្រចាំ ដើម្បីអន្តរាគមន៍តាមជាក់ស្តែងក្នុងការចូលរួមទប់ស្កាត់បទល្មើសគ្រប់ប្រភេទតាមផ្នែកពាក់ព័ន្ធនីមួយៗ យ៉ាងយកចិត្តទុកដាក់ រួមទាំងការចាក់វ៉ាក់សាំងសត្វ ការធ្វើអនាម័យ និងជីវសុវត្ថិភាពជាដើម។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០១៥នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៤-២០១៥

គិតមកទល់ពេលនេះ ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដីសរុបចំនួន២៦៥.៩១១ហិកតា ស្មើនឹង ៥៤,៣០ភាគរយ នៃផ្ទៃដីអនុវត្តបានចំនួន៤៨៩.៦៩៩ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន១.១៦៧.៨៣៩តោន និងទិន្នផលជាមធ្យមចំនួន៤,៣៩២តោនក្នុងមួយហិកតា (ឆ្នាំមុនទទួលបានទិន្នផលគិតជាមធ្យមបាន៤,៤០៦តោនក្នុងមួយហិកតា) ក្នុងនោះ៖

- ផ្ទៃដីភ្ជួររាស់សរុបចំនួន៥៨១.១០៤ហិកតា លើសឆ្នាំមុនចំនួន៣៧.១១៨ហិកតា
- ផ្ទៃដីសាបសរុបចំនួន៤.០៣០ហិកតា តិចជាងឆ្នាំមុនចំនួន៨២៤ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤៨៩.៦៩៩ហិកតា ស្មើនឹង១១៧,៤៤ភាគរយនៃផែនការ៤១៦.៩៦៥ហិកតា លើសឆ្នាំមុនចំនួន២.១៩៣ហិកតា។

#### ១.២ ដំណាំរួមផ្សំរដូវប្រាំង :

- ផ្ទៃដីសម្រេចបានចំនួន៧២.៧៣៣ហិកតា ស្មើនឹង១៦៨,៤៨% នៃផែនការចំនួន៤៣.១៦៩ហិកតា តិចជាងឆ្នាំមុនចំនួន៩.៤០៧ហិកតា។

- ដំណាំឧស្សាហកម្ម : ផ្ទៃដីសម្រេចបាន១៣.៧១៦ហិកតា ស្មើនឹង៦៧,៧៣% នៃផែនការ២០.២៥១ហិកតា លើសឆ្នាំមុនចំនួន១.៤២៥ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១១៧,១៦ | - |
| សរុប I | | ៤០៦,៦០ | ៣៤៤,៣១ | ១១៧,១៦ | - |
| II-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,២៧ | ៥.៣២៧,០៥ | ៤.៧៥២,៧៣ | ១.១៤៥,៨០ |
| ២ | ក្រុមហ៊ុន ស៊ីហ្វវ៉ាប់បើលីមីធីត (រតនគិរី) | ៧៨,៥៣ | ២.០៦៤,៣០ | ១០៤,០៨ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៨២,១២ | ២៤៤,៦៨ | ១២០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៥៧១,៥២ | ៣.១៣៩,៨៣ | ១.៥៥៩,២៤ | ៦៧២,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ១.២៦៣,៧៥ | ២១០,០០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវីសស៍ (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ៧០៨,៣២ | ៤០០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៦៣៨,៤៤ | ២២៨,៤០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្ដូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ៥៧៣,៧៥ | ១៣១,៦០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.២៧២,៦០ | - | - |
| ១០ | ក្រុមហ៊ុនក្រេក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៣៤៧,៩២ | ១.៦២៩,៣៩ | ៦៦០,០០ |
| សរុប II | | ២៨.១៥៩,៥៤ | ២៥.៦៧៥,០៨ | ១១.៤៧៤,៣៨ | ៣.៥៦៧,៨០ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧០៨,០០ | ១៤១.២០៤,០០ | ៦,២០ | ៤,១០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៧៦.១៤៧,០០ | ១.២០៩,៧០ | ៦,៧០ |
| សរុប III | | ៦១.៩៧៩,០០ | ២១៧.៣៥១,០០ | ១.២១៥,៩០ | ១០,៨០ |
| សរុប I+II+III | | ៩០.៥៤៥,១៤ | ២៤៣.៣៧០,៣៩ | ១២.៨០៧,៤៤ | ៣.៥៧៨,៦០ |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ធ្វើតេស្តសំណាកយថាប្រភេទចំនួន៣០សំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់រោងចក្រក្រុមហ៊ុន ឡុង ស្រេង និងអ៊ឹម តិច
- រៀបចំពិធីសារពិសោធន៍ស្តីពីការប្រើប្រាស់ជីលើកៅស៊ូផ្តល់ផលក្លូន GT1 និង RRIM712 លើប្រភេទដីគីមី
- វាស់ទំហំដើមលើចម្ការពិសោធន៍ IRAE10, IRAE13, IRAE14 និងស្រង់ទិន្នន័យទិន្នផលជ័រគ្រប់ចម្ការពិសោធន៍
- លាបថ្នាំសម្គាល់បច្ច័យតាមចម្ការពិសោធន៍កៅស៊ូ និងបាញ់ថ្នាំការពារជំងឺកូនកៅស៊ូ
- រៀបចំបើកមុខចៀរជ័រឡូត៍ពិសោធន៍ក្លូន IRAA09 និងរៀបចំដីសម្រាប់ដាំកៅស៊ូឆ្នាំ២០១៥
- ត្រួតពិនិត្យឡូត៍ពិសោធន៍ក្លូន និងថែទាំសម្ភារកម្មពូជដំណាំគម្របដី
- រៀបចំទីតាំងស្រង់ទិន្នន័យជំងឺ Oidium ក្នុងឡូត៍ពិសោធន៍ក្លូន IRAA01-IRAA08
- ដឹកនាំនិស្សិតសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និងសាលាជាតិកសិកម្មកំពង់ចាម។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យាបាល

### ៣.១ ការងារវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

- ជ្រូកសរុបចំនួន៣១៨ក្បាល នៅក្នុងស្ថានីយពិសោធន៍ពូជជ្រូក ក្នុងនោះជ្រូកបាចំនួន១០ក្បាល ជ្រូកមេចំនួន១០១ក្បាល និងកូនជ្រូកចំនួន១៩៧ក្បាល

- គោសរុបចំនួន១៥៦ក្បាល នៅក្នុងស្ថានីយចិញ្ចឹមគោ ក្នុងនោះគោប្រាម៉ាន់កាត់ចំនួន១១៥ក្បាល និងគោកំផែងសែនចំនួន៤១ក្បាល

- វិទ្យាស្ថានបានខិតខំពង្រឹងសកម្មភាពពិសោធន៍ស្រាវជ្រាវដូចខាងក្រោម៖

+ កែច្នៃទឹកមេជីវិតនៅវិទ្យាស្ថានពិសោធន៍ពូជគោនៅភ្នំតាម៉ៅ

+ រៀបចំសកម្មភាពគម្រោងគាំទ្រដោយសហភាពអឺរ៉ុបទាក់ទងនឹងការងារកែច្នៃទឹកមេជីវិតគោ

+ លើកសំណើទៅភាគីចិនដើម្បីបង្កើតមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតគោ មន្ទីរពិសោធន៍វិភាគចំណីសត្វ មន្ទីរពិសោធន៍សេនេទិច និងមន្ទីរពិសោធន៍កាកសំណល់ថ្នាំ

+ រៀបចំស្នើសុំទិញឧបករណ៍វិភាគចំណីតាមរយៈគម្រោងសហភាពអឺរ៉ុបនិងគម្រោង SPS។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន៧១.៧៤៩ក្បាល ជំងឺអុតក្តាមចំនួន៧៩៩ក្បាល និងជំងឺបូសខ្យល់ចំនួន២៥ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន១០.៤១៨ក្បាល ជំងឺប៉េស្តចំនួន១៧.៧២១ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន១១.៩៦១ក្បាល ជំងឺអុតក្តាមចំនួន៧២៩ក្បាល ជំងឺអូហ្សេស្គីចំនួន១.៨៩៨ក្បាល ជំងឺរាគកូនជ្រូកចំនួន២.៦០៤ក្បាល ជំងឺកញ្រ្ជឹលចំនួន៧៦០ក្បាល ជំងឺជាតិដែកចំនួន១.៥៩០ក្បាល និងជំងឺផ្លូវដង្ហើមចំនួន១.១៥២ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៤០.៩៨១ក្បាល ជំងឺញីវកាសចំនួន៩១.៨៨៨ក្បាល ជំងឺអាសន្នរោគចំនួន៨៩.៥៨៧ក្បាល និងជំងឺប៉េស្តទាចំនួន៤៦.១៩៨ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅតាមខេត្ត-រាជធានី

- បានពិនិត្យវត្ថុវិភាគសរុបចំនួន៨០៤សំណាក និងផ្នែកសរីរោគសាស្ត្រសរុបចំនួន៤ក្បាល

- ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន២៤១ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន៣៦១ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

- តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស និងទទួលទូរស័ព្ទហៅចូលសរុបចំនួន៣ករណី មកពីខេត្តសៀមរាប កំពង់ចាម និងខេត្តកំពង់ស្ពឺ សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងវិធានការការពារជំងឺផ្តាសាយបក្សី

- ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូកចំនួន១២លើក មាន់ចំនួន១៩លើក ទាចំនួន៥៣លើក កន្លែងពិឃាតមាន់ចំនួន៣លើក កន្លែងលក់មាន់ចំនួន២០លើក ទ្រុងចិញ្ចឹមចំនួន៨៤លើក សត្តឃាតដ្ឋានចំនួន២៨លើក ផ្លូវជាតិចំនួន២៧លើក និងកន្លែងផ្ទុះជំងឺចំនួន៣លើក។

## ៤ ផ្នែករុក្ខាព្រៃឈើ

### ៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ១៩២ប្រភេទ (ប្រហែល១០៥.០១១ក្បាល)

- រៀបចំអាហារដ្ឋានត្មាតនៅព្រៃការពារព្រះវិហារ ស្ទឹងត្រែង និងក្រចេះ ដោយរាប់ឃើញសត្វត្មាតសរុបចំនួនប្រមាណ៤៦ក្បាល

- ការពារសម្បុកសត្វត្រដក់តូចចំនួនប្រមាណ១៨សម្បុក សត្វក្រយ៉ងចង្កំ ក ស ចំនួន១៦សម្បុក ត្មាតចំនួន៥ និងរំពេរចំនួន៧សម្បុក នៅខេត្តស្ទឹងត្រែង ក្រចេះ និងព្រះវិហារ។

### ៤.២ ការងារសហគមន៍ព្រៃឈើ

- ធ្វើការអប់រំផ្សព្វផ្សាយពីសារសំខាន់នៃការអភិរក្សសត្វព្រៃ ពង្រឹងការអនុវត្តច្បាប់ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់គណៈកម្មាធិការសហគមន៍ ក្រុមសន្សំប្រាក់ ការចិញ្ចឹមមាន់ ការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារ ស្រូវសង្គ្រោះសត្វព្រៃ ការអភិរក្សសត្វក្អានតាមដងទន្លេមេគង្គ និងការគ្រប់គ្រងកម្មវិធីទេសចរណ៍ធម្មជាតិ ដោយមានអ្នកចូលរួមសរុបចំនួន ២.២៨១នាក់ (ស្ត្រីចំនួន៦៨៤នាក់)

- មានភ្ញៀវទេសចរចំនួន៦១នាក់មកទស្សនាតំបន់អភិរក្សជីវចម្រុះវ៉ឺនសៃ-សៀមប៉ាង កំពង់ធំ-សៀមរាប តំបន់អភិរក្សសត្វក្រៀលរាងត្រពាំងថ្មនិងព្រៃការពារព្រះវិហារដោយសហគមន៍មូលដ្ឋានទទួលប្រាក់ចំណូលចំនួន៨៤៥ដុល្លារ។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្នុងខែកុម្ភៈ ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សាៈ សត្វចំណូលថ្មីចំនួន៦២ក្បាល សត្វកើតថ្មីចំនួន៥ក្បាល សត្វដោះលែងចំនួន៦៤ក្បាល សត្វស្លាប់ចំនួន៨ក្បាល ព្យាបាលសត្វចំនួន១៨ក្បាល យកសំណាកទៅពិសោធន៍ចំនួន១៥ក្បាល ធ្វើឲ្យសន្លប់ចំនួន១៥ក្បាល ទម្លាក់សត្វល្អិតចំនួន៤៨ក្បាល វះកាត់សាកសពសត្វចំនួន៥៣ក្បាល ចាក់វ៉ាក់សាំងចំនួន៤០ក្បាល សាងសង់ទ្រុងសត្វថ្មីលើចំនួន ៣៧,២០ម$^{២}$ ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន១៤ម$^{២}$ ឆ្ការអនាម័យព្រៃចំនួន២៣.៦៥០ម$^{២}$ ដាំកូនឈើចំនួន៨០១ដើម បណ្តុះផ្កាលម្អចំនួន១៥ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៥១៨នាក់

- ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្ដាមមេ-បាពូជ និងកូនស្វាក្ដាមចំនួន៥៤.៨០៨ក្បាល និងបាននាំចេញចំនួន ៧៥ក្បាល។

### ៤.៤ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

- ដោះលែងក្រពើភ្នំចំនួន២ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង(Radio Tracking)

- រៀបចំផែនការបង្កើតចម្ការពូជផ្ទុងទំហំ៥ហិកតា និងប្រមូលគ្រាប់ពូជឈើផ្ទុងបានចំនួន១.៥០០គ.ក្រ និងកកោះចំនួន១.០០០គ.ក្រពីធម្មជាតិសម្រាប់បម្រើឲ្យផែនការដាំឈើជាចម្ការ និងបណ្តុះកូនឈើសម្រាប់ចែកចាយដល់កសិករដាំអាស្រ័យផលឆ្នាំ២០១៥នេះ

- ចុះស្រាវជ្រាវអំពីសត្វល្អិត Leptocybe invasa នៅក្នុងស្ថានីយដាំឈើចំនួន៣ទីតាំង (មានក ស្នួលទ្រេត ក្រសាំង) និងក្រុមហ៊ុន Kamarkara។ ជាលទ្ធផលនៃការស្រាវជ្រាវបានរកឃើញនិងប្រមូលសំណាកនៃសត្វល្អិតនៅក្នុងចម្ការឈើប្រេងខ្យល់(EucalyptusK7) ខេត្តបន្ទាយមានជ័យ ហើយក្រុមការងារនឹងបន្តចុះស្រាវជ្រាវលើកទី២នៅតំបន់ផ្សេងៗទៀត។

### ៤.៥ ការងារដាំដើមឈើ

- ក្រុមហ៊ុន ស៊ីងបាយអូថេក(ខេមបូឌា) ខូអិលធីឌី ជាដៃគូបានធ្វើការផលិតពូជកូនឈើបានចំនួន៣០០.០០០ដើម

- ក្រុមហ៊ុន អូជី (ខេមបូឌា) ផ្លេនថេសិន ហ្វរីស ខមភេនី លីមីធីត បានរៀបចំដាំពិសោធន៍ពូជលើទំហំដី ៥ហិកតា

- ការដាំឈើជាចម្ការថ្មីរបស់រដ្ឋបាលព្រៃឈើនៅតាមបណ្តាស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន៣ទីតាំង ដោយបណ្តុះកូនឈើបានចំនួន៣០០.០០០ដើម ឈូសឆាយដីព្រៃបានចំនួន៤០ហិកតា និងថែទាំដាំជួសចម្ការឈើចាស់នៅស្ថានីយដាំឈើចំនួន១០ មានចម្ការឈើចាស់ចំនួន២.៨១៨ហិកតា ត្រូវបានធ្វើការថែទាំ និងការពារជាប្រចាំ ជាពិសេសគឺការកាប់រានដីនិងភ្លើងព្រៃ។

### ៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន២ ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន ៣.៥២៤ម$^{៣}$ និងដើមចន្ទន៍ក្រស្នា(រុក្ខជាតិរស់)ជូនក្រុមហ៊ុនចំនួន១ ស្មើនឹង៧២ដើម។

### ៤.៧ ការងារចំណូលព្រៃឈើ

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន ១៤.០២២ម$^{៣}$ កូនឈើចំនួន១២៤.២៩៩ដើម អុសចម្រុះចំនួន២៣.៣៥០ស្ទែរ និងជ័រទឹកចំនួន៨០តោន

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន១ ស្មើនឹង២០សុន្ទឹក ដែលមានបរិមាណឈើកែច្នៃចំនួន២.៣៩៦ម$^{៣}$

- ផ្តល់លិខិតសម្រាប់បំពេញលើករណីបង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើចំនួន២៨៦សន្លឹក និងបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន៤១៥សន្លឹកជូនខណ្ឌរដ្ឋបាលព្រៃឈើចំនួន១២

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន២.១១៥.៩៣៧.៥៧៧រៀល និងចំណូលពីសេវាសាធារណៈចំនួន៧៥១.៩៣០.០២៦រៀល និង៤២.៤៩៨,៣២ដុល្លារ។

## ៤.៨ ការងារផលិតកម្មព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

- រៀបចំកិច្ចប្រជុំជាមួយតំណាងភាគីកូរ៉េ ស្តីពីការអនុវត្តគម្រោងរេដបុក នៅក្នុងខេត្តកំពង់ធំ ដោយៈ ១/អនុម័តផែនការសកម្មភាពនិងផែនការថវិការយៈពេល៣ខែ ២/បែងចែកភារកិច្ចរបស់សមាជិកគម្រោង ៣/រៀបចំនិងអនុម័តគោលការណ៍ណែនាំសម្រាប់អនុវត្តគម្រោង ៤/រៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងជាមួយសមភាគី

- រៀបចំកិច្ចប្រជុំជាមួយអង្គការ WCS នៅលេខាធិការដ្ឋាន REDD+កម្ពុជា ដោយៈ ១/រៀបចំផែនការសិក្ខាសាលាស្តីពីហិរញ្ញប្បទានព្រៃឈើជាតិនិងអនុម័តលើគម្រោងសំណើថវិកាសម្រាប់សិក្ខាសាលា ២/ពិនិត្យឡើងវិញលើលទ្ធផលសិក្សាស្តីពីការវាយតម្លៃពីជម្រើសហិរញ្ញប្បទានព្រៃឈើជាតិជាមួយស្ថាប័នពាក់ព័ន្ធ ៣/រៀបចំផែនការប្រចាំឆ្នាំ២០១៥ ជាមួយសមាជិកនៃក្រុមការងារហិរញ្ញប្បទាននៃក្រុមការងារបច្ចេកទេស TWG-FR។

## ៤.៩ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៨២ករណី ដោយបញ្ជូនទៅតុលាការចំនួន១០៥ករណី និងពិន័យអន្តរការណ៍ចំនួន៧៧ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៤៥ម៣ ឈើអារចំនួន៦៣១ម៣ ឈើក្រាក់គ្រញូងចំនួន១ម៣ សត្វព្រៃចម្រុះប្រភេទចំនួន១៩៤គ.ក្រនិង៥២៩ក្បាល និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន១៦៧ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃដែលបានទទួលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ធ្វើការឆ្លើយតបរហ័សលើព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលមានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន១០៩ករណី។ ការចុះផ្សាយនេះបានឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ ហើយអត្ថបទសារព័ត៌មានដែលចុះផ្សាយចំនួន២៩ករណីត្រូវបានជ្រើសរើសរួចបញ្ជូនទៅបណ្តាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីបំភ្លឺ។

# ៥ ផ្នែកជលផល

## ៥.១ អាជីវកម្មនេសាទ

### ៥.១.១ នេសាទទឹកសាប

- ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៤-២០១៥ ក្នុងខែចំនួន១.២៨៥តោន សរុបបានចំនួន១២.២៨៥តោន ស្មើ១២២,៨៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៦.៧១៥តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៥ ក្នុងខែចំនួន៣០.០០០តោន សរុបបានចំនួន៦០.០០០តោនស្មើ២០% នៃផែនការ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០.០០០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៥ ក្នុងខែចំនួន៨.០០០តោន សរុបបានចំនួន១៨.០០០តោនស្មើ២០% នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១២.០០០តោន(មូលហេតុនៃការថយចុះគឺបណ្តាលមកពីការប្រែប្រួលអាកាសធាតុ)។

### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៥

- ក្នុងខែចំនួន៨.០០០តោន សរុបចំនួន១៣.០០០តោន ស្មើ១៣% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥.០០០តោន។

## ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្កា ក្នុងខែចំនួន៨.៥០០តោន សរុបបានចំនួន១៦.៥០០តោន ស្មើ១៦,៥០% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

- ការចិញ្ចឹមក្រពើ ក្នុងខែចំនួន៩.០០០ក្បាល សរុបបានចំនួន១៧.០០០ក្បាល ស្មើ៦,៨០% នៃផែនការ ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៨.០០០ក្បាល

- ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួនប្រមាណ១០.០០០.០០០កូន សរុបបានចំនួនប្រមាណ១៩.០០០.០០០កូន ស្មើ១០,៥៦% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួនប្រមាណ១.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ ក្នុងខែចំនួន៦.៥០០តោន សរុបបានចំនួន១២.៥០០តោន ស្មើ១៥,២៤% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.៥០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ ក្នុងខែចំនួន៨០០តោន សរុបបានចំនួន១.៥០០តោន ស្មើ១៨,៧៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០០តោន

- ការផលិតទឹកត្រី ក្នុងខែចំនួន៥.០០០.០០០លីត្រ សរុបបានចំនួន៨.០០០.០០០លីត្រ ស្មើ១៦% នៃផែនការ ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែចំនួន៨៥០តោន សរុបបានចំនួន១.៨៥០តោន ស្មើ១២,៣៣% នៃផែនការ១៥.០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៥០តោន

- ផលនេសាទកែច្នៃ ក្នុងខែចំនួន៦៥០តោន សរុបបានចំនួន១.១៥០តោន ស្មើ២៣% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៥០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់ខែមករា ឆ្នាំ២០១៥នេះសំណុំរឿងបទល្មើសជលផលសរុបចំនួន១៧៩ករណីនៅតំបន់ទឹកសាប។ ដោយឡែក ក្នុងខែនេះសមត្ថកិច្ចជំនាញបានបញ្ជូនសំណុំរឿងទៅតុលាការចំនួន១៥ករណី និងបញ្ជូនជនសង្ស័យទៅតុលាការចំនួន២៦នាក់។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល ក្នុងខែចំនួន២៦៨.០៨៣.៥០០រៀល សរុបបានចំនួន៣៤១.២៤៣.៥០០រៀល ស្មើ ១១,៣៧% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២១៣.៨៤៨.៧៥០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះត្រួតពិនិត្យការងារពិសោធន៍ និងធ្វើទិវាស្រែវាយតម្លៃស្រឡាយស្រូវប្រាំងផ្ការំដួល នៅខេត្តស្វាយរៀង ខេត្តបាត់ដំបង និងខេត្តតាកែវ

- ចូលរួមប្រជុំពិភាក្សាផ្តល់យោបល់សេចក្តីព្រាងចុងក្រោយ ស្តីពីគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា ជាមួយក្រុមការងារ HARVEST-USAID នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ និងចូលរួមក្នុងកម្មវិធីមហាសន្និបាតរបស់សហព័ន្ធស្រូវ-អង្ករកម្ពុជា នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

- ជួបពិភាក្សាការងារជាមួយ Mr. Amit Trikha ស្តីពីការងារសហការធ្វើពិសោធន៍ពូជស្រូវ Hybrid និងពិភាក្សាការងារជាមួយ Dr. Imelda Bacudo ស្តីពីការបង្កើតមជ្ឈមណ្ឌលផលិតកម្មពូជស្រូវ

- បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកវិទ្យាផលិតកម្មគ្រាប់ពូជស្រូវ ដែលមានអ្នកចូលរួមសរុបចំនួន២៨នាក់។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣៨២ច្បាប់ សរុបចំនួន៨៥២ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣២៦ច្បាប់ សរុបចំនួន៦៥៩ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន៧៥ច្បាប់ សរុបចំនួន១៧៧ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៤៧៧ច្បាប់ សរុបចំនួន១.២៤៦ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៣៧ច្បាប់ សរុបចំនួន១៣៣ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន១២ច្បាប់ សរុបចំនួន៤៧ច្បាប់

- ផ្តល់លិខិតសម្រាប់បំពេញលើករណីបង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើចំនួន២៨៦សន្លឹក និងបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន៤១៥សន្លឹកជូនខណ្ឌរដ្ឋបាលព្រៃឈើចំនួន១២

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន២.១១៥.៩៣៧.៥៧៧រៀល និងចំណូលពីសេវាសាធារណៈចំនួន៧៥១.៩៣០.០២៦រៀល និង៤២.៤៩៨,៣២ដុល្លារ។

### ៤.៨ ការងារផែនការកាបូនព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

- រៀបចំកិច្ចប្រជុំជាមួយតំណាងភាគីកូរ៉េ ស្តីពីការអនុវត្តគម្រោងរេដបូក នៅក្នុងខេត្តកំពង់ធំ ដោយៈ ១/អនុម័តផែនការសកម្មភាពនិងផែនការថវិការយៈពេល៣ខែ ២/បែងចែកភារកិច្ចរបស់សមាជិកគម្រោង ៣/រៀបចំនិងអនុម័តគោលការណ៍ណែនាំសម្រាប់អនុវត្តគម្រោង ៤/រៀបចំសេចក្តីព្រាងកិច្ចព្រមព្រៀងជាមួយសមភាគី

- រៀបចំកិច្ចប្រជុំជាមួយអង្គការ WCS នៅលេខាធិការដ្ឋាន REDD+កម្ពុជា ដោយៈ ១/រៀបចំផែនការសិក្ខាសាលាស្តីពីហិរញ្ញប្បទានព្រៃឈើជាតិនិងអនុម័តលើគម្រោងសំណើថវិកាសម្រាប់សិក្ខាសាលា ២/ពិនិត្យឡើងវិញលើលទ្ធផលសិក្សាស្តីពីការវាយតម្លៃពីជម្រើសហិរញ្ញប្បទានព្រៃឈើជាតិជាមួយស្ថាប័នពាក់ព័ន្ធ ៣/រៀបចំផែនការប្រចាំឆ្នាំ២០១៥ ជាមួយសមាជិកនៃក្រុមការងារហិរញ្ញប្បទាននៃក្រុមការងារបច្ចេកទេស TWG-FR។

### ៤.៩ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៨២ករណី ដោយបញ្ជូនទៅតុលាការចំនួន១០៥ករណី និងពិន័យអន្តរការណ៍ចំនួន៧៧ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៤៥ម៣ ឈើអារចំនួន៦៣១ម៣ ឈើក្រាក់គ្រញូងចំនួន១ម៣ សត្វព្រៃចម្រុះប្រភេទចំនួន១៩៤គ.ក្រនិង៥២៩ក្បាល និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន១៦៧ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃដែលបានទទួលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ធ្វើការឆ្លើយតបរហ័សលើព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលមានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន១០៩ករណី។ ការចុះផ្សាយនេះបានឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ ហើយអត្ថបទសារព័ត៌មានដែលចុះផ្សាយចំនួន២៩ករណីត្រូវបានជ្រើសរើសរួចបញ្ជូនទៅបណ្តាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីបំភ្លឺ។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៤-២០១៥ ក្នុងខែចំនួន១.២៨៥តោន សរុបបានចំនួន១២.២៨៥តោន ស្មើ១២២,៨៥% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៦.៧១៥តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៥ ក្នុងខែចំនួន៣០.០០០តោន សរុបបានចំនួន៦០.០០០តោន ស្មើ២០% នៃផែនការ៣០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣០.០០០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៥ ក្នុងខែចំនួន៨.០០០តោន សរុបបានចំនួន១៨.០០០តោន ស្មើ២០% នៃផែនការ៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១២.០០០តោន(មូលហេតុនៃការថយចុះគឺបណ្តាលមកពីការប្រែប្រួលអាកាសធាតុ)។

#### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៥

- ក្នុងខែចំនួន៨.០០០តោន សរុបចំនួន១៣.០០០តោន ស្មើ១៣% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥.០០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន៨.៥០០តោន សរុបបានចំនួន១៦.៥០០តោន ស្មើ១៦,៥០% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៨២២នាក់ នារីចំនួន១.៣២៥នាក់ ស្មើនឹង២០% រួមមាន៖

+ អង្គភាពថ្នាក់កណ្តាលចំនួន៤.១៤៨នាក់ ក្នុងនោះនារីចំនួន៧៨៧នាក់ ស្មើនឹង១៩%

+ អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៧៦នាក់ ក្នុងនោះនារីចំនួន៥៧៨នាក់ ស្មើនឹង១៧,៨៦%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន១២នាក់ ក្នុងនោះបោះបង់ការងារចំនួន០៦នាក់ និងសុំលាឈប់ពីការងារចំនួន០៦នាក់

- ចេញច្បាប់សម្រាកប្រចាំឆ្នាំចំនួន០២នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០៣នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់ ផ្ទេរចូលក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៤នាក់

- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន១៤នាក់

- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន១២នាក់ និងក្នុងប្រទេសចំនួន២៤នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ចូលរួមប្រជុំពិភាក្សាអំពីការអនុវត្តអនុសញ្ញា UNCCD និងការរៀបចំឯកសារកម្មវិធីសកម្មភាពជាតិ ប្រយុទ្ធ ប្រឆាំងនឹងឱនភាពដី (NAP)

- ចូលរួមកិច្ចប្រជុំពិភាក្សាសេចក្តីព្រាងកិច្ចព្រមព្រៀង (First Draft Agreement) ស្តីពីការជំរុញនិងការសម្រប សម្រួលពាណិជ្ជកម្មក្នុងការអភិវឌ្ឍន៍តំបន់ត្រីកោណ CLV-DTA និងចូលរួមសន្និសីទស្តីពី Bilateral Cooperation between Korea and Cambodia Regarding Agriculture and Rural Development

- បញ្ជូនមន្ត្រីចំនួន៥រូប ចូលរួមបើកវគ្គបណ្តុះបណ្តាលកសិករលើប្រធានបទស្តីពីនិរន្តរភាពនៃផលិតកម្មដំឡូងមីសម្រាប់កសិករខ្នាតតូច នៅខេត្តកំពង់ចាម ខេត្តប៉ៃលិន ខេត្តបាត់ដំបង

- បញ្ជូនមន្ត្រីចំនួន២៣រូប ចូលរួមនិងសហការរៀបចំសិក្ខាសាលាស្តីពីកម្រិតកាកសំណល់ជាតិពុល និងកិច្ចប្រជុំលើកទី១៩ នៃក្រុមការងារជំនាញស្តីពីការធ្វើសុខដុមនីយកម្មកម្រិតកាកសំណល់ជាតិពុល នៃថ្នាំពុលកសិកម្ម នៅខេត្តសៀមរាប

-បញ្ជូនមន្ត្រីចំនួន៣រូប ចូលរួមសិក្ខាសាលាស្តីពីផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធីឆ្នាំ២០១៥ នៅខេត្តកែប

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៣៩នាក់ នៅក្នុងប្រទេសចំនួន១៣។

## ១០ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២៣១នាក់(ស្រី៣៩២នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ បន្តរៀបចំកម្មវិធីសិក្សាថ្មី២០១៥ ព្រមទាំងសិក្សាអំពីលទ្ធភាពកាត់បន្ថយចំនួនម៉ោងនិងក្រេឌីតក្នុងក្របខ័ណ្ឌកំណែទម្រង់កម្មវិធីសិក្សាឲ្យ

រូបភាព។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវដោយសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## IV- ទិសដៅអនុវត្តបន្ត

### ១.ផ្នែកដាំដុះ :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្មៀង (អង្គរ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឲ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផលឲ្យអស់លទ្ធភាពនៅកន្លែងដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

### ២.ផ្នែកផលិតកម្មនិងបសុព្យាបាល :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឲ្យបានទូលំទូលាយ

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

- ពង្រឹងត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឲ្យបានសមស្របតាមនីតិវិធី។

**៣.ផ្នែកព្រៃឈើ** :

- ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើតាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃនិងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ជំរុញពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

- បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទដូចភ្លៀងរលឹម។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យមានប្រសិទ្ធភាព

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងការប្រមូលចំណូលបង់ចូលថវិកាជាតិឲ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

- គ្រោងរៀបចំសន្និបាតកសិករដើម្បីជ្រើសរើសកសិករឆ្នើម និងសន្និបាតបូកសរុបការងារកសិកម្មប្រចាំឆ្នាំ និងលើកទិសដៅអនុវត្តបន្តនាពេលខាងមុខ

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

- បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត វ៉េង សាខុន